*ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១*

# សេចក្តីប្រកាសព័ត៌មានរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត

នាថ្ងៃនេះ មានព័ត៌មានមួយចំនួន ត្រូវបានចុះនៅក្នុងបណ្តាញសារព័ត៌មានទាក់ទិនទៅនឹងសហចៅក្រមស៊ើបអង្កេត ជាពិសេសទាក់ទងទៅនឹងការណ៍ដែលថា "*...សហចៅក្រមស៊ើបអង្កេតទាំងពីរបានចុះកាលបរិច្ឆេទថយក្រោយ និង បានកែប្រែជាសម្ងាត់នូវឯកសារដែលដាក់ចូលក្នុងសំណុំរឿង ០០៣...*"។ ការចោទប្រកាន់ទាំងនេះត្រូវបានធ្វើឡើងដោយយោងលើគំនិតមតិភាគតិចរបស់ចៅក្រមអន្តរជាតិ (នៃអង្គបុរេជំនុំជម្រះ) ទាក់ទងទៅនឹងបណ្តឹងឧទ្ធរណ៍របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់។ តាមធម្មតា សហចៅក្រមស៊ើបអង្កេតមិនគួរធ្វើការឆ្លើយតបណាមួយទៅនឹងការបញ្ចេញទស្សនៈណាមួយរបស់ចៅក្រមណាមួយឡើយ ជាពិសេសចំពោះមតិដែលជាការវាយតម្លៃផ្ទាល់ខ្លួន និងដែលមិនមែនជាសម្អាងហេតុនៃសេចក្តីសម្រេចណាមួយនោះ។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ដើម្បីចៀសវាងនូវការភ័ន្តច្រឡំរបស់សាធារណៈជន ការិយាល័យសហចៅក្រមស៊ើបអង្កេត សូមធ្វើការគូសបញ្ជាក់ដូចខាងក្រោម ៖

- បន្ទាប់ពីទទួលបាននូវការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់បុគ្គលខាងលើ ដែលត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ និង ០០២ ដោយសហចៅក្រមស៊ើបអង្កេតរួចហើយ នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញនូវដីកាសម្រេចបដិសេធការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ នៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០៣ និង ០០៤។ ដោយហេតុថា ពាក្យសុំមានតែមួយ ប៉ុន្តែស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងក្នុងសំណុំរឿង ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសម្រេចពីរផ្សេងគ្នា ដែលដីកាសម្រេចមួយសម្រាប់សំណុំរឿង ០០៣ និងដីកាសម្រេចមួយទៀតសម្រាប់សំណុំរឿង ០០៤ ទោះបីជាដីកាសម្រេចទាំងពីរមានសម្អាងហេតុដូចគ្នាក៏ដោយ។
- ដោយហេតុថា នៅក្នុងការរៀបចំដីកាសម្រេចសម្រាប់សំណុំរឿង ០០៣ មានលេខយោងមួយចំនួនដែលមិនត្រូវបានកែប្រែអស់ និងត្រូវបានកត់សម្គាល់ឃើញដោយក្រឡាបញ្ជី សហចៅក្រមស៊ើបអង្កេតបានអនុញ្ញាតឲ្យក្រឡាបញ្ជីធ្វើការកែតម្រូវ តាមនីតិវិធីដែលមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ និងស្របទៅតាមការអនុវត្តកន្លងមក។
- សំណើសុំកែតម្រូវត្រូវបានធ្វើឡើងដោយក្រឡាបញ្ជី ដោយមានភ្ជាប់ទៅជាមួយនូវសេចក្តីព្រាងដែលមានបញ្ជាក់អំពីចំនុចកែតម្រូវ (track changes) និងបញ្ជាក់ច្បាស់ចំណុចដែលត្រូវកែប្រែ។ ឯកសារនេះ ត្រូវបាន

ដាក់ចូលទៅក្នុងសំណុំរឿងក្រោមលេខសំណុំរឿង D11/2/3/corr-1 និងត្រូវបានជូនដំណឹងដល់ភាគីនៃសំណុំរឿង តាមនីតិវិធីធម្មតា រួមទាំងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់នោះ ផងដែរ។

- នៅក្នុងការកែតម្រូវ សហចៅក្រមស៊ើបអង្កេត មិនអាចប្តូរកាលបរិច្ឆេទនៃការចេញដីកាសម្រេចរបស់ខ្លួនឡើយ ដោយត្រូវរក្សាទុកនូវកាលបរិច្ឆេទនៃការចេញដីកាសម្រេចដំបូងដដែល និងធ្វើការកែប្រែនូវចំនុចឬទំព័រដែលត្រូវកែតម្រូវតែប៉ុណ្ណោះ ព្រោះនេះគឺជាការកែតម្រូវនូវចំនុចភ័ន្តច្រឡំខ្លះ និងមិនមែនជាការចេញដីកាសម្រេចថ្មីជំនួសដីកាសម្រេចចាស់នោះទេ។ ការអនុវត្តបែបនេះ ក៏ធ្លាប់បានធ្វើឡើងដោយអង្គបុរេជំនុំជម្រះផងដែរ ដូចជានៅក្នុងឯកសារនៃការកែតម្រូវចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១០ (D402/1/4-Corr-1) ទៅលើសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ (D402/1/4)។

ដើម្បីជានានូវតម្លាភាព និងដើម្បីជៀសវៀងការធ្វើការបំផ្លើសនានានៅក្នុងបណ្តាញសារព័ត៌មាន សហ-ចៅក្រមស៊ើបអង្កេត សូមធ្វើការដាក់ជាសាធារណៈនូវឯកសារដែលមានពាក់ព័ន្ធនឹងបញ្ហាខាងលើនេះ។ ឯកសារទាំងអស់នេះ នឹងត្រូវផ្សព្វផ្សាយនៅលើគេហ៍ទំព័ររបស់ អ.វ.ត.ក. www.eccc.gov.kh។